Chham Chhany

# លោក ហ៊ុន សែន ថាសម រង្ស៊ីបបួលលោកធ្វើវិសោធ
# នកម្មរដ្ឋធម្មនុញ្ញស្តីពីការប្រើប្រាស់ផែនទី

........................

ដោយ៖ ស៊ុន ណារិន | ថ្ងៃព្រហស្បតិ៍ ទី13 សីហា 2015, 11:03 AM VOD

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃព្រហស្បតិ៍នេះបានថ្លែងថាប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី បានបបួលរូបលោកធ្វើវិសោធនកម្មមាត្រា២នៃរដ្ឋធម្មនុញ្ញស្តីពីការប្រើប្រាស់ផែនទីបោះបង្គោលព្រំដែនជាមួយប្រទេសជិតខាង។

មាត្រា២នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថាបូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាមិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត១/១០០.០០០ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ១៩៦៣-១៩៦៩។

ក្នុងពិធីចែកសញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងថាការបោះបង្គោលព្រំដែនមិនមែនត្រូវធ្វើតែជាមួយប្រទេសវៀតណាមនោះទេ គឺត្រូវធ្វើជាមួយប្រទេសថៃនិងឡាវផងដែរ។ លោកបន្តថាបើតាមរដ្ឋធម្មនុញ្ញ កម្ពុជាមិនអាចប្រើប្រាស់ផែនទីខ្នាត១/២០០.០០០ជាមួយប្រទេសថៃបាននោះទេ តែលោកថាជាការល្អដែរដែលកម្ពុជាបានធ្វើអនុស្សរណៈយោគយល់ជាមួយប្រទេសថៃ ទើបកម្ពុជាអាចប្រើប្រាស់ផែនទីខ្នាត១/២០០.០០០បាន។ លោកបានបញ្ជាក់ថា៖ "សោកស្តាយដែលរដ្ឋធម្មនុញ្ញរបស់យើងមិនបានដាក់ ត្រង់នេះហើយបានជាមានការនិយាយអំពីបញ្ហាទាក់ទងនឹងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។ យើងធ្វើរបងផ្ទះបានតែម្ខាងទេ គឺធ្វើជាមួយវៀតណាម ប៉ុន្តែមានបានធ្វើជាមួយថៃណា ថៃអត់យកផែនទីខ្នាត១/១០០.០០០ទៅដោះស្រាយបានទេ តែយើងមានMOUរវាងកម្ពុជានិងថៃលើបញ្ហាព្រំដែនគោកអនុស្សរណៈនៃការយោគយល់គ្នា ដែលត្រូវប្រើប្រាស់ផែនទីខ្នាត១/២០០.០០០ ដោយគណៈកម្មការបារាំងសៀម”។

លោក ហ៊ុន សែន បន្តថាប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី បានបបួលរូបលោកធ្វើវិសោធនកម្មមាត្រា២នៃរដ្ឋធម្មនុញ្ញ ដោយលោកបានរិះគន់ថាហេតុអ្វីបានខុសពីអ្វីដែលសមាជិកគណបក្សមិនចង់ឲ្យធ្វើវិសោធនកម្ម។ លោកបានរៀបរាប់ថា៖ "សូម្បីតែឯកឧត្តមសម រង្ស៊ី និយាយឲ្យច្បាស់ទៅ ឯកឧត្តមសម រង្ស៊ី ក៏វៃSMS(សារតាមទូរស័ព្ទ)មកខ្ញុំ។ ដើម្បីឲ្យកូនចៅគាត់ភ្លឺភ្នែក.... មេគាត់បបួលខ្ញុំ តែខ្ញុំអត់ទាន់ព្រម ព្រោះមិនត្រូវធ្វើនៅពេលហ្នឹងទេ។ ថ្ងៃ១៧ខែ០៧ម៉ោង៧, ៤៩នាទី ខ្ញុំអានឲ្យស្តាប់ ហើយអស់លោក ខាងគណបក្សសង្គ្រោះជាតិស្តាប់ឲ្យបាន។ ...ខ្ញុំសូមសម្តេចមេត្តាពិនិត្យលទ្ធភាពធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រង់មាត្រា២ស្តីពីផែនទី ដែលយើងត្រូវបញ្ជាក់ឲ្យកាន់តែក្បោះក្បាយ ដោយមានការចូលរួមពីគណបក្សប្រជាជននិងគណបក្សសង្គ្រោះជាតិរួមគ្នា..”។

វីអូឌី(VOD)មិនទាន់អាចសុំការបកស្រាយតាមរយៈអ៊ីម៉េលពីលោក សម រង្ស៊ី ដែលកំពុងស្នាក់នៅក្រៅប្រទេសបាននៅឡើយទេ។ អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិ លោក អ៊ូ ច័ន្ទឫទ្ធិ មានប្រសាសន៍ថាលោកមិនទាន់បានទទួលព័ត៌មាននេះនៅឡើយទេ ដូច្នេះលោកមិនអាចអត្ថាធិប្បាយលើបញ្ហានេះបានទេ រហូតដល់មានការបញ្ជាក់ពីលោក សម រង្ស៊ី។

ប្រធានស្ថាប័នស្រាវជ្រាវវេទិកាអនាគតនិងជាអ្នកវិភាគឯករាជ្យ លោក អ៊ូ វីរៈ មានប្រសាសន៍ថាការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើប្រជាមតិជាមុនសិន។

កន្លងទៅ លោក ហ៊ុន សែន ធ្លាប់បានថ្លែងថារដ្ឋធម្មនុញ្ញកម្ពុជាបានសរសេរខ្វះចន្លោះ ដែលលោកអះអាងថាពិបាកយកទៅតតាំងជាមួយវៀតណាម ។ ចំណែកកាលពីថ្ងៃទី០៣ខែសីហា ឆ្នាំ២០១៥ លោក ហ៊ុន សែន បានថ្លែងថាលោកនឹងលុបចោលកិច្ចព្រមព្រៀងជាមួយវៀតណាម ប្រសិនបើមានការវិសោធនកម្មរដ្ឋធម្មនុញ្ញ ដោយចែងជំនួសថាកម្ពុជាប្រើប្រាស់ផែនទីខ្នាត១/៥០.០០០វិញ។ លោកបញ្ជាក់ថា៖ ”បើសិនជារដ្ឋធម្មនុញ្ញបានចែងថាផែនទីនៃព្រះរាជាណាចក្រកម្ពុជាប្រើប្រាស់ផែនទីខ្នាត១/៥០.០០០ ខ្ញុំព្រះករុណាក៏សុខចិត្តលុបចោលកិច្ចព្រមព្រៀងសន្ធិសញ្ញាជាមួយវៀតណាមដែរ។ តែមាត្រាទី២នៃរដ្ឋធម្មនុញ្ញគេឲ្យប្រើថាផែនទីអធិបតេយ្យរបស់កម្ពុជាមានចែងនៅក្នុងផែនទីខ្នាត១/១០០.០០០ បោះពុម្ពក្នុងចន្លោះឆ្នាំ១៩៣៣-៥៣ ដែលអន្តរជាតិទទួលស្គាល់៦៣-៦៩”។

កន្លងទៅ ប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែន លោក វ៉ា គឹមហុង បានថ្លែងថាសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ដែលរដ្ឋាភិបាលកម្ពុជានិងវៀតណាមបានចុះហត្ថលេខារួមគ្នា អនុញ្ញាតឲ្យភាគីទាំងពីរគូសចម្លងខ្សែព្រំដែនពីផែនទីបោន១/១០០.០០០មកលើផែនទីUTM១/៥០.០០០ ដើម្បីជាជំនួយដល់ក្រុមបច្ចេកទេសយកមកអនុវត្តនៅលើដីជាក់ស្តែង។

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោក អ៊ុំ សំអាន ដែលអះអាងថាកម្ពុជាបាត់បង់ទឹកដីឲ្យវៀតណាម មានប្រសាសន៍ថាកម្ពុជាអាចយកសារាចររបស់អគ្គទេសាភិបាលឥណ្ឌូចិនមុនឆ្នាំ១៩៣៣មកប្រើបានទាក់ទងនឹងតំបន់ដាក់ហូតដាក់ដាំ ដោយថារដ្ឋធម្មនុញ្ញកម្ពុជាបានចែងតែការប្រើប្រាស់ផែនទីតែប៉ុណ្ណោះ៕

សរសេរមកកាន់លោក ស៊ុន ណារិន តាមរយៈsun_narin@vodhotnews.com